# វិសមភាពនៃសំណង់ប្រាសាទក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី២

តាមការសិក្សាលើរចនាសម្ព័ន្ធប្រាសាទ បែបបទទម្រង់នៃប្រាង្គសំខាន់ និងក្បាច់លម្អនៅលើប្រាសាទទាំងនោះ ធ្វើអោយអ្នកស្រាវជ្រាវជាច្រើនបានសន្និដ្ឋានថា ប្រាសាទមួយចំនួនត្រូវបានស្ថាបនាឡើងក្នុងចន្លោះរាជ្យព្រះបាទសូរ្យវរ្ម័នទី២ (គ.ស១១១៣ដល់១១៥០) ឬយើងអាចនិយាយបានថាក្នុងរចនាបថអង្គរវត្ត។ ប្រាសាទទាំងនោះ មានដូចជាប្រាសាទអង្គរវត្ត ធម្មនន្ទ ចៅសាយទេវតា បន្ទាយសំរែ វត្តអធ្វារ បេងមាលា (ប្រាសាទទាំងនេះស្ថិតនៅក្នុងតំបន់អង្គរ) ប្រាសាទព្រះខ័នកំពង់ស្វាយ (កំពង់ធំ) ប្រាសាទវត្តឯកភ្នំ (បាត់ដំបង) ប្រាសាទភិម័យ (ស្រុកសៀម) ជាដើម។

លក្ខណៈជារួមនៃប្រាសាទទាំងនេះ (លើកលែងប្រាសាទអង្គរវត្ត) ជាទូទៅ មានប្រាង្គសំខាន់នៅចំកណ្តាល បន្តដោយសំណង់វែងលយទៅមុខ (មណ្ឌប) និង ព័ទ្ធដោយកំពែង១ជាន់ធ្វើពីថ្មបាយក្រៀមលាយថ្មភក់ និងមានក្លោងទ្វារនៅតាមទិសទាំង៤ (រូបលេខ១៖ ប្លង់គំរូទូទៅ) ដូចជា៖ ប្រាសាទធម្មនន្ទ (រូបលេខ២-៣) ចៅសាយទេវតា (រូបលេខ៤-៥) វត្តអធ្វា (រូបលេខ៦-៧) ព្រះខ័នកំពង់ស្វាយ[១] (រូបលេខ៨-៩) វត្តឯកភ្នំ និងភិម័យ។ ប្រាសាទផ្សេងទៀតមានកំពែងច្រើនជាន់៖ ប្រាសាទអង្គរវត្ត (កំពែងថ្មបាយក្រៀម១ជាន់ និងថែវខាងក្នុង២ជាន់ (មិនគិតថែវរបស់រូតបាកាណ) បន្ទាយសំរែ២ជាន់ (រូបលេខ១០-១១) និងបេងមាលា២ ជាន់។ ជាធម្មតា ក្លោងទ្វារ (គោបុរៈ) ទាំង៤ទិសរបស់កំពែងទាំងនេះ តែងតែឆ្លុះគ្នាជាមួយនិងប្រាង្គកណ្តាលតាមទិសកើតលិច និងជើងត្បូង។

ក្នុងអត្ថបទខ្លីនេះ ខ្ញុំសូមលើកយកចំនុចពិសេសមួយ ដែលអ្នកស្រាវជ្រាវតែងចាប់អារម្មណ៍តែនៅលើប្រាសាទអង្គរវត្ត គឺភាពមិនស្មើគ្នា (ប្រវែង) នៃចន្លោះខាងជើង និងខាងត្បូងរវាងថែវទី២ជាមួយនិងរូតបាកាណ។

តើចំនុចនៃវិសមភាព (ប្រវែងមិនស្មើគ្នា) នោះនៅកន្លែងណា?

---

[១] Henri, Mauger, (1943:200-201)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

# អត្ថបទ៖ វិសមភាពនៃសំណង់ប្រាសាទក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី២

វិសមភាពនៃប្រាសាទអង្គរវត្ត គឺសំដៅទៅលើភាពមិនស្មើគ្នារវាងថែវទី២ និងខឿនរបស់រួតបាកាណ (ប្រាង្គកណ្ដាល) ដែលមានប្រវែងមិនស្មើគ្នារវាងចន្លោះនៃគោបុរៈខាងត្បូងទៅជណ្ដើរឡើងខាងត្បូងរបស់ខឿនបាកាណ និងប្រវែងពីគោបុរៈខាងជើងទៅជណ្ដើរឡើងខាងជើងរបស់រួតបាកាណ (រូបលេខ១២-១៣)។ យើងអាចសិក្សាប្រៀបធៀបបានតាមរយៈជញ្ជាំងខាងជើង និងខាងត្បូងរបស់ថែវទី២ ដែលមានប្រវែងមិនស្មើគ្នា។ លោកស្រី Mannikka បានសិក្សាយ៉ាងលម្អិតលើការរៀបចំរចនាសម្ព័ន្ធនានា របស់ប្រាសាទអង្គរវត្ត ពិសេសគឺការប្រើខ្នាតដែលទាក់ទងនិងលោកធាតុនិយម និងតារាសាស្ត្រ។ ក្នុងនោះលោកស្រីបានបកស្រាយអំពីភាពមិនស្មើគ្នារវាងស្ពាបខាងជើង និងស្ពាបខាងត្បូង របស់ជញ្ជាំងខាងលិច និងខាងកើត នៃថែវទី២។ អ្វីដែលសំខាន់នោះ គឺលោកស្រីបានសន្និដ្ឋានថា ភាពមិនស្មើគ្នានេះ គឺទាក់ទងទៅនិងដំណើរគោចរនៃព្រះអាទិត្យក្នុងរយៈ១ឆ្នាំ នៅទិសខាងជើង និងខាងត្បូង (យកប្រាង្គកណ្ដាលជាខ្សែចែក) ដែលទិសខាងជើងមានរយៈពេលវែងជាងទិសខាងត្បូង។ ដូចនេះហើយទើបបានគេស្ដាបនាជញ្ជាំងខាងជើង (ថែវលិច និងកើត) វែងជាងជញ្ជាំងខាងត្បូង។[២]

នេះជាចំនុចដែលដែលគេគិតថាភាពមិនស្មើគ្នានេះទាក់ទងនិងដំណើរគោចរនៃព្រះអាទិត្យ ពោលគឺព្រះអាទិត្យរះ ឬដើរចេញពីប្រាង្គកណ្ដាលរបស់អង្គរវត្តទៅទិសខាងជើង មានរយៈពេលយូរជាងគោចរពីប្រាង្គកណ្ដាលទៅទិសខាងត្បូង។ ចំនុចនេះខ្ញុំបានបកស្រាយម្ដងហើយក្នុងអត្ថបទទស្សនៈនៃការស្ដាបនាប្រាសាទអង្គរវត្តជាមួយនិងចំនួន ៦ និង១២។[៣] ការកសាងប្រាសាទអង្គរវត្តគឺទាក់ទងទៅនិងដំណើរនៃព្រះអាទិត្យក្នុងរយៈពេល១ឆ្នាំ (៣៦៥ឬ៣៦៦) ឬ១២ខែ។ ពីខ្សែត្រង់ពីប្រាង្គកណ្ដាលមកទ្វារចូលកណ្ដាលនៅទិសខាងលិច គឺជាខ័ណ្ឌសីមារវាងខែទាំង១២។ ថ្ងៃទី២១ដល់២៣ នៃខែមិនា និងកញ្ញា គឺជាចន្លោះពេលដែលព្រះអាទិត្យបិតនៅក្នុងអ័ក្សខ័ណ្ឌចែកនេះ។ ប្រសិនបើយើងបូកបញ្ចូលចំនួនថ្ងៃរបស់ខែទាំង៦ (២៣មិនា ដល់២៣កញ្ញា) និង (២៣កញ្ញាដល់២៣មិនា) របស់

---

[២] Eleanor Mannikka 1996:122

[៣] សុខ កែវ សុវណ្ណារ៉ា ២០២០:១

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

ទិសទាំង២ យើងឃើញថា មានរយៈពេល១៨០ថ្ងៃដូចគ្នា មិនមានលើស ឬខ្វះទេ គឺសរុបមានចំនួន៣៦០ថ្ងៃ រីឯ៥ឬ៦ថ្ងៃទៀតជាវេលាចន្លោះដែលព្រះអាទិត្យស្ថិតនៅលើឬក្បែរកំពូលរបស់ប្រាង្គកណ្តាលប្រាសាទអង្គរវត្ត (រូបលេខ១៤)។ វាហាក់បីដូចជាមិនស្របនិងសំណើររបស់អ្នកស្រី Mannikka លើកឡើងទេ។ ចំពោះខ្ញុំក៏មិនទាន់យល់ស្របទាំងស្រុងលើសម្មតិកម្មនេះដែរ។ នៅក្នុងក្បួនស្ថាបត្យកម្មបុរាណឥណ្ឌា ការស្ថាបនាប្រាសាទនានាគេតែងតែលួចអោយផ្នែកខាងជើងមានប្រវែង ឬទំហំធំជាងបន្តិច។ ទ្រឹស្តីនេះ យើងអាចយកមកធ្វើជាការបញ្ជាក់លើប្រាសាទអង្គរវត្តបាន។ ប៉ុន្តែវាហាក់បីដូចជាមិនត្រឹមត្រូវទាំងស្រុងនោះទេ ពីព្រោះខ្ញុំបានធ្វើការសិក្សា និងអង្កេតលើសំណង់ប្រាសាទផ្សេងៗក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី២ គឺមានលក្ខណៈពិសេសមួយមិនទាក់ទងនិងដំណើរគោចររបស់ព្រះអាទិត្យ ដែលជាហេតុនាំអោយគេស្ថាបនាប្រាសាទអង្គរវត្តមានចន្លោះវែងខ្លីជាងគ្នានោះទេ។ ហេតុផលសំខាន់នោះគឺទាក់ទងនិងទិសដៅ នៃច្រកចូលសំខាន់ទៅរកប្រាង្គកណ្តាល។ ជាទូទៅ គេតែងធ្វើអោយទីធ្លាឬចន្លោះខាងឆ្វេងដៃ (យើងឈរបែរមុខទៅរកប្រាង្គកណ្តាល ឧទាហរណ៍ប្រាសាទអង្គរវត្តត្រូវចូលពីខាងលិច យើងត្រូវបែរដើរទៅខាងកើត) ធំជាងខាងស្តាំដៃជានិច្ច។ ការធ្វើបែបនេះ ជាទូទៅគឺជាចន្លោះរវាងប្រាង្គកណ្តាលជាមួយនិងកំពែងដែលនៅក្បែរប្រាង្គកណ្តាល ឬខឿនរបស់ប្រាង្គកណ្តាល។ ជាក់ស្តែងប្រាសាទអង្គរវត្ត ថែវទី២ជាខឿនរបស់រូតប្រាង្គកណ្តាល ដូចនេះគេសង់អោយមានចន្លោះតូចធំ ដោយធៀបនិងខឿនរបស់ប្រាង្គបាកាណ។ ចំពោះថែវទី១ (ថែវមានក្បាច់ចម្លាក់/អ្នកស្រី Mannikka ហៅថែវទី៣) កំពែងខាងក្រៅ និងកសិន្ធុ គឺមានទំហំចន្លោះស្មើគ្នា ធៀបជាមួយប្រាង្គកណ្តាល។ ចំនុចដូចគ្នានេះ យើងអាចឃើញនៅប្រាសាទវត្តអធ្វាដែរ គឺចន្លោះខាងជើងធំជាងចន្លោះខាងត្បូង បើប្រៀបធៀបប្រាង្គកណ្តាលជាមួយនិងកំពែងខាងក្រៅ។ យើងអាចអោយសម្មតិកម្មមួយបានថា **ប្រាសាទអង្គរវត្ត** និង**ប្រាសាទវត្តអធ្វា**[៤] ដែលមានច្រកចូលសំខាន់ពីទិសខាងលិច គឺចន្លោះខាងជើងធំជាងខាងត្បូង (ជញ្ជាំងថែវ ឬកំពែង) ពោលគឺនៅខាងឆ្វេងដៃរបស់យើងដែលបែរទៅរកប្រាង្គកណ្តាល។ ផ្ទុយពី

---

[៤] សុខ កែវ សុវណ្ណារ៉ា ២០២១

ប្រាសាទ២នេះ ប្រាសាទធម្មនន្ទ ប្រាសាទចៅសាយទេវតា ប្រាសាទបន្ទាយសំរ៉ែ ប្រាសាទបេងមាលា ប្រាសាទព្រះខ័នកំពង់ស្វាយ និងអាចរួមទាំង (ប្រាសាទវត្តឯកភ្នំ និងប្រាសាទភិម័យ) ដែលមានច្រកចូលសំខាន់ពីទិសខាងកើត ចន្លោះរវាងថែវ ឬកំពែងដែលនៅក្បែរប្រាង្គ កណ្ដាល គឺខាងត្បូងវែងឬធំជាងខាងជើង ផ្ទុយពីប្រាសាទអង្គរវត្ត និងវត្តអធ្វា។ ដូចនេះ យើងអាចបង្កើតទ្រឹស្ដីថ្មីមួយទាក់ទងនិងភាពមិនស្មើគ្នានេះ គឺមិនទាក់ទងនិងដំណើរគោចររបស់ព្រះអាទិត្យដែលមានរយៈពេលវែងនៅទិសខាងជើង និងរយៈពេលខ្លីនៅទិសខាងត្បូងដូចការស្នើរឡើងរបស់លោកស្រី Mannikka នោះទេ។

***សម្មតិកម្មថ្មីរបស់ខ្ញុំ ភាពមិនស្មើគ្នានេះមិនទាក់ទងនិងដំណើរគោចររបស់ព្រះអាទិត្យទេ វាទាក់ទងនិងទិសដៅនៃច្រកចូលសំខាន់ ពោលគឺផ្នែកឬចន្លោះនៅខាងឆ្វេងដៃរបស់យើង ត្រូវធំជាងខាងស្ដាំជានិច្ច មានន័យថា យើងត្រូវឈរនៅលើផ្លូវចូលសំខាន់ហើយបែរមុខទៅរកប្រាង្គកណ្ដាល។***

តើហេតុអ្វីបានជាគេស្ថាបនាប្រាសាទទាំងនេះអោយមានភាពមិនស្មើគ្នាបែបនេះ?

វាជាបញ្ហាមួយដែលពិបាកពន្យល់អំពីទស្សនៈនៃការស្ថាបនាប្រាសាទអោយមានភាពមិនស្មើគ្នារវាងចន្លោះខាងឆ្វេង និងខាងស្ដាំណាស់ ព្រោះយើងពុំមានសិលាចារឹករៀបរាប់អំពីទស្សនៈបែបហ្នឹង ហើយប្រពៃណីនេះពុំមានបន្តរហូតដល់បច្ចុប្បន្ននោះទេ។ បើយើងពិនិត្យមើលអោយកាន់ តែជ្រៅ មិនត្រឹមតែប្លង់សំណង់ប្រាសាទទេដែលមានភាពមិនស្មើគ្នា សូម្បីតែមឈូសថ្មរបស់ព្រះបាទសូរ្យវរ្ម័នទី២[៩] ក៏មានលក្ខណៈបែបនេះដែរ។ មឈូសថ្មនេះមានរាងជាការេ ដែលជ្រុងខាងក្រៅនីមួយៗមានប្រវែង៨៣សង់ទីម៉ែត្រកម្ពស់៤១សង់ទីម៉ែត្រ។ អ្វីដែលចម្លែកនោះគឺផ្ទៃខាងក្នុងត្រូវបានគេធ្វើមិនអោយស្មើគ្នា គឺជ្រុងម្ខាងមានប្រវែង៦៥សង់ទីម៉ែត្រ និងម្ខាងទៀតមានប្រវែងតែ៦២សង់ទីម៉ែត្រទេ (រូបលេខ១៦)។ យើងមិនដឹងថា ព្រះអង្គ និងរាជគ្រូ មានទស្សនៈអ្វីលើភាពមិនស្មើគ្នានេះទេ។ វាហាក់បីដូចជា ទស្សនៈផ្ទាល់ខ្លួនក្នុងការរៀបចំទំហំផ្ទាសង្ខាងឱ្យមានប្រវែងមិនស្មើបែបនេះ ដូចគ្នានឹងទស្សនៈនៃការស្ថាបនាប្រាសាទអង្គរវត្តដែរ។

---

៩ សុខ កែវ សុវណ្ណារ៉ា ២០២០

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

ជាសង្ខេប អត្ថបទនេះបង្ហាញពីភាពមិនស្មើគ្នា លើសំណង់ប្រាសាទក្នុងរជ្ជព្រះបាទសូរ្យវរ្ម័នទ២។ ម្យ៉ាងអត្ថបទនេះចង់បង្ហាញពីការមិនយល់ស្របជាមួយមតិរបស់អ្នកស្រី Mannikka ដែលបានសន្និដ្ឋានថា ភាពមិនស្មើគ្នារវាងជញ្ជាំងខាងត្បូង និងជញ្ជាំងខាងជើង ទាក់ទងទៅនិងដំណើរគោចររបស់ព្រះអាទិត្យ ពីចំនុចកណ្ដាលទៅជើង និងទៅត្បូង។ យោបល់នេះហាក់ដូចជាមិនត្រឹមត្រូវ ព្រោះបើយើងស្រាវជ្រាវភាពមិនស្មើគ្នាលើសំណង់ប្រាសាទក្នុងរជ្ជរបស់ព្រះអង្គ យើងនិងឃើញយ៉ាងច្បាស់ថា ផ្នែកនៅខាងឆ្វេងដៃតែងតែមានផ្ទាធំជាងផ្នែកខាងស្ដាំ គឺមិនពាក់ព័ន្ធ និងដំណើរគោចររបស់ព្រះអាទិត្យទេ។ ទោះយ៉ាងណា ទស្សនៈនៃការរៀបចំបែបនេះ យើងមិនទាន់មានព័តមានសម្រាប់ពន្យល់នៅឡើយទេ។ វាទាមទារអោយយើងធ្វើការសិក្សានិងស្រាវជ្រាវបន្ថែម។

ដូចនេះ អត្ថបទនេះគ្រាន់តែបង្ហាញពីភាពមិនស្មើគ្នា ចំពោះការសន្និដ្ឋានអំពីមូលហេតុនេះនៅមិនទាន់ច្បាស់នៅឡើយ។




រូបលេខ១៖ ប្លង់ទូទៅនៃសំណង់ប្រាសាទ

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា






រូបលេខ២២-៣៖ ប្លង់បង្ហាញកន្លែងមិនស្មើគ្នា (ប្រាសាទធម្មនន្ទ)






រូបលេខ២៤-៥៖ ប្លង់បង្ហាញកន្លែងមិនស្មើគ្នា (ប្រាសាទចៅសាយទេវតា)






រូបលេខ២៦-៧៖ ប្លង់បង្ហាញកន្លែងមិនស្មើគ្នា (ប្រាសាទវត្តអធ្វា)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា




រូបលេខ៨៖ ប្លង់បង្ហាញកន្លែងមិនស្មើគ្នា (ប្រាសាទព្រះខ័នកំពង់ស្វាយ)






រូបលេខ៩-១០៖ ប្លង់បង្ហាញកន្លែងមិនស្មើគ្នា (ប្រាសាទបន្ទាយសំរែ)

រូបលេខ១១-១២៖ ប្លង់បង្ហាញកន្លែងមិនស្មើគ្នា (ប្រាសាទអង្គរវត្ត)







(ប្រភពរូបភាព៖ លោក ឈូក សុម៉ាឡា)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា




រូបលេខ២១៣៖ គំនូសបង្ហាញភាពមិនស្មើគ្នារបស់អ្នកស្រី Mannikka




រូបលេខ២១៤៖ ចំនួនថ្ងៃនៃព្រះអាទិត្យគោចរ




*រូបលេខ១៥៖ មឈូសរបស់ព្រះបាទសូរ្យវរ្ម័នទី២*

## ឯកសារយោង

Eleanor Mannikka, (1996), *Angkor Wat- Time, Space, and Kingship*, University of Hawaii Press,

Henri, Mauger, (1943), *Prah Khan de Kompoṅ Svay*, BEFEO, Paris, PL.XXXVIII.

*សុខ កែវ សុវណ្ណារ៉ា, (២០២០), អាចកំបាំងមឈូសព្រះបាទសូរ្យវរ្ម័នទី២នៅប្រាសាទអង្គរវត្ត,* ក្នុងAMS ,ភ្នំពេញ។

*សុខ កែវ សុវណ្ណារ៉ា (២០២០), ទស្សនៈនៃការស្ថាបនាប្រាសាទអង្គរវត្តជាមួយនិងចំនួន៦ និង១២,* ក្នុង AMS, ភ្នំពេញ។

*សុខ កែវ សុវណ្ណារ៉ា, (២០២១), ប្រាសាទវត្តអធ្វា,* ក្នុងAMS , ភ្នំពេញ។

*អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា*